ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០១ ......សហវ.ប្រក.[illegible]

ក្រសួងមហាផ្ទៃ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវារដ្ឋបាលលើការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល បញ្ជាក់អត្តសញ្ញាណបុគ្គល និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៥២ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ៣៩២២ ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីបែបបទ និងនីតិវិធីនៃការស្នើសុំផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល បញ្ជាក់អំពីអត្តសញ្ញាណបុគ្គល ឬបញ្ជាក់អំពីភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល និងលក្ខខណ្ឌបច្ចេកទេសនៃការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

សេវារដ្ឋបាលលើការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល បញ្ជាក់អត្តសញ្ញាណបុគ្គល និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ដែលផ្តល់ដោយក្រសួងមហាផ្ទៃ ត្រូវបានរៀបចំជាកម្រងសេវារដ្ឋបាលដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល កម្រិត១ | ១.០០០ | ភ្លាមៗ | ១ប្រតិបត្តិការ |
| ២- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល កម្រិត២ | ៦.០០០ | ភ្លាមៗ | ១ប្រតិបត្តិការ |
| ៣- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល កម្រិត៣ | ៨.០០០ | ភ្លាមៗ | ១ប្រតិបត្តិការ |
| ៤- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល កម្រិត៤ | ១០.០០០ | ភ្លាមៗ | ១ប្រតិបត្តិការ |
| ៥- | លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល | ៥.០០០ | ៥ថ្ងៃ | ៦ខែ |
| ៦- | លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល | ២០០.០០០ | ៥ថ្ងៃ | ៦ខែ |
| ៧- | សេវាភ្ជាប់ប្រព័ន្ធផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលប្រចាំឆ្នាំ | ៦០០.០០០ | ១០ថ្ងៃ | ១ឆ្នាំ |

**ប្រការ២ ._**

ទម្រង់ បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្ដល់សេវារដ្ឋបាលទៅតាមប្រភេទសេវានីមួយៗ ត្រូវអនុវត្តតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

លក្ខខណ្ឌនៃការស្នើសុំផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល បញ្ជាក់អត្តសញ្ញាណបុគ្គល និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ ._**

ទិន្នន័យអត្តសញ្ញាណបុគ្គល ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ គឺជាទិន្នន័យផ្លូវការតែមួយគត់ដែលអាចប្រើប្រាស់បាន ស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## នៃប្រកាសអន្តរក្រសួងលេខ ៦០១ ............ សហវ.ប្រក.អនច ចុះថ្ងៃទី ២៧ ...... ខែកញ្ញា ...... ឆ្នាំ២០២៤ ស្តីពីការផ្តល់សេវារដ្ឋបាលលើការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល បញ្ជាក់អត្តសញ្ញាណបុគ្គល និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល

| ល.រ | បរិយាយ | លក្ខខណ្ឌ |
|---|---|---|
| ១- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលកម្រិត១ | ប្រើប្រាស់សម្រាប់ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលមូលដ្ឋាន ក្នុងលក្ខខណ្ឌដូចខាងក្រោម៖<br>- សន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា<br>- រាប់តែចំនួនប្រតិបត្តិការដែលជោគជ័យប៉ុណ្ណោះ<br>- ទិន្នន័យផ្ទៀងផ្ទាត់រួមមាន ១- គោត្តនាម និងនាមជាភាសាខ្មែរ ២- គោត្តនាម និងនាមជាអក្សរឡាតាំង ៣- ភេទ ៤- ថ្ងៃខែឆ្នាំកំណើត ៥- លេខអត្តសញ្ញាណប័ណ្ណ និង ៦- កាលបរិច្ឆេទសុពលភាពអត្តសញ្ញាណប័ណ្ណ។ |
| ២- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលកម្រិត២ | ប្រើប្រាស់សម្រាប់ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលមូលដ្ឋាន និងរូបថតផ្ទៃមុខបុគ្គលបច្ចុប្បន្ន ក្នុងលក្ខខណ្ឌដូចខាងក្រោម៖<br>- សន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា<br>- រាប់តែចំនួនប្រតិបត្តិការដែលជោគជ័យប៉ុណ្ណោះ<br>- ទិន្នន័យផ្ទៀងផ្ទាត់រួមមាន ១- គោត្តនាម និងនាមជាភាសាខ្មែរ ២- គោត្តនាម និងនាមជាអក្សរឡាតាំង ៣- ភេទ ៤- ថ្ងៃខែឆ្នាំកំណើត ៥- លេខអត្តសញ្ញាណប័ណ្ណ ៦- កាលបរិច្ឆេទសុពលភាពអត្តសញ្ញាណប័ណ្ណ និង ៧- រូបថតផ្ទៃមុខបុគ្គលបច្ចុប្បន្ន។ |
| ៣- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលកម្រិត៣ | ប្រើប្រាស់សម្រាប់ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលមូលដ្ឋាន រូបថតផ្ទៃមុខបុគ្គលបច្ចុប្បន្ន និងរូបថតផ្ទៃមុខបុគ្គលលើអត្តសញ្ញាណប័ណ្ណ ក្នុងលក្ខខណ្ឌដូចខាងក្រោម៖<br>- សន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា<br>- រាប់តែចំនួនប្រតិបត្តិការដែលជោគជ័យប៉ុណ្ណោះ<br>- ទិន្នន័យផ្ទៀងផ្ទាត់រួមមាន ១- គោត្តនាម និងនាមជាភាសាខ្មែរ ២- គោត្តនាម និងនាមជាអក្សរឡាតាំង ៣- ភេទ ៤- ថ្ងៃខែឆ្នាំកំណើត ៥- លេខអត្តសញ្ញាណប័ណ្ណ ៦- កាលបរិច្ឆេទសុពលភាពអត្តសញ្ញាណប័ណ្ណ ៧- រូបថតផ្ទៃមុខបុគ្គលបច្ចុប្បន្ន និង ៨- រូបថតលើអត្តសញ្ញាណប័ណ្ណ។ |
| ៤- | ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលកម្រិត៤ | ប្រើប្រាស់សម្រាប់ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលមូលដ្ឋាន រូបថតផ្ទៃមុខបុគ្គលបច្ចុប្បន្ន រូបថតផ្ទៃមុខបុគ្គលលើអត្តសញ្ញាណប័ណ្ណ និងភាពរស់រវើកនៃបុគ្គល ក្នុងលក្ខខណ្ឌដូចខាងក្រោម៖<br>- សន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា<br>- រាប់តែចំនួនប្រតិបត្តិការដែលជោគជ័យប៉ុណ្ណោះ<br>- ទិន្នន័យផ្ទៀងផ្ទាត់រួមមាន ១- គោត្តនាម និងនាមជាភាសាខ្មែរ ២- គោត្តនាម និងនាមជាអក្សរឡាតាំង ៣- ភេទ ៤- ថ្ងៃខែឆ្នាំកំណើត ៥- លេខអត្តសញ្ញាណប័ណ្ណ ៦- កាលបរិច្ឆេទសុពលភាពអត្តសញ្ញាណប័ណ្ណ ៧- រូបថតផ្ទៃមុខបុគ្គលបច្ចុប្បន្ន ៨- រូបថតលើអត្តសញ្ញាណប័ណ្ណ និង ៩- វីដេអូចលនាផ្ទៃមុខ។ |

| ល.រ | បរិយាយ | លក្ខខណ្ឌ |
|---|---|---|
| ៥- | លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល | ប្រើប្រាស់សម្រាប់លក្ខខណ្ឌដូចខាងក្រោម៖<br>- ចេញលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គលតាមការស្នើសុំ<br>- ទិន្នន័យបញ្ជាក់រួមមាន ១- គោត្តនាម និងនាមជាភាសាខ្មែរ ២- គោត្តនាម និងនាមជាអក្សរឡាតាំង ៣- ភេទ ៤- ថ្ងៃខែឆ្នាំកំណើត ៥- ទីកន្លែងកំណើត ៦- អាសយដ្ឋានបច្ចុប្បន្ន ៧- លេខអត្តសញ្ញាណប័ណ្ណ និង ៨- រូបថតលើអត្តសញ្ញាណប័ណ្ណ<br>- លិខិតបញ្ជាក់នេះចេញជូនរូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំចំនួន ២ច្បាប់ សម្រាប់ការស្នើសុំម្តង។ |
| ៦- | លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល | ប្រើប្រាស់សម្រាប់លក្ខខណ្ឌដូចខាងក្រោម៖<br>- ចេញលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គលតាមការស្នើសុំ<br>- ទិន្នន័យបញ្ជាក់រួមមាន ១- គោត្តនាម និងនាមជាភាសាខ្មែរ ២- គោត្តនាម និងនាមជាអក្សរឡាតាំង ៣- ភេទ ៤- ថ្ងៃខែឆ្នាំកំណើត ៥- ទីកន្លែងកំណើត ៦- អាសយដ្ឋានបច្ចុប្បន្ន ៧- លេខអត្តសញ្ញាណប័ណ្ណ ៨- រូបថតលើអត្តសញ្ញាណប័ណ្ណ ៩- ស្នាមមេដៃឆ្វេង និងស្តាំ និង ១០- គំរូហត្ថលេខា<br>- លិខិតបញ្ជាក់នេះចេញជូនរូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំចំនួន ២ច្បាប់ សម្រាប់ការស្នើសុំម្តង។ |
| ៧- | សេវាភ្ជាប់ប្រព័ន្ធផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលប្រចាំឆ្នាំ | ប្រើប្រាស់សម្រាប់ភ្ជាប់ប្រព័ន្ធផ្ទៀងផ្ទាត់ទិន្នន័យប្រចាំឆ្នាំ ដោយឆ្លងកាត់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដែលស្នើសុំមកកាន់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។ |